

## ករណីសិក្សា ៖ អត្ថប្រយោជន៍កញ្ចប់ជំនួយសង្គម

ជាជនជាតិដើមភាគតិចកួយ រស់នៅក្នុងខេត្តព្រះវិហារ។ អ្នកស្រី លាង វ៉ែង មានអាយុ២៨ឆ្នាំមានស្វាមីជាកម្មករសំណង់ ។ គ្រួសារអ្នកស្រីមានកូនចំនួន០៣នាក់ កូនច្បងមានអាយុ៨ឆ្នាំនិងមានពិការភាពស្វិតដៃជើងតាំងពីកំណើត(ក្រិន)ចំណែកកូនស្រី ទីពីរកំពុងរៀននៅសាលាបឋមសិក្សានិងម្នាក់ទៀតមិនទាន់បានចូលរៀននៅឡើយ ។
បច្ចុប្បន្ន សមាជិកក្នុងគ្រួសាររបស់គាត់មានគ្នា០៩នាក់ ក្នុងនោះមានម្ដាយជាស្ត្រីមេមាយពូ មានកាយសម្បាទាមិន ពេញលេញល្អ(ក្រិន)និងប្អូនប្រុសស្រី២នាក់ទៀត។ សព្វថ្ងៃអ្នកស្រីមានមុខរបរជាអ្នកធ្វើស្រែចម្ការនិងដើរស៊ីឈ្នួលគេនៅក្នុង សហគមន៍។

អ្នកស្រីមានការយល់ដឹងអំពីកិច្ចគាំពារសង្គម ដូចជា៖ ការ ជួយគាំទ្រផ្នែកហិរញ្ញវត្ថុប្រចាំខែ សេវាថែទាំសុខភាពការ ចាក់ថ្នាំបង្ការនិងពិនិត្យសុខភាពដោយមិនមានការចំណាយថវិកាអ្វីឡើយ ជាពិសេសពិនិត្យសុខភាពអំឡុងពេលមានផ្ទៃពោះ ការសម្រាលកូន និងកុមារអាយុក្រោម ២ឆ្នាំ។ អ្នកស្ត្រីបានបន្ថែមទៀតថា នៅពេលដែលគ្រួសាររបស់គាត់មានជំងឺម្តងៗ ពួកគាត់តែងតែទៅពិនិត្យនិងព្យាបាលនៅមណ្ឌលសុខភាព និងមន្ទីពេទ្យបង្អែក១៦មករា ខេត្តព្រះ វិហារ។

ទោះបីជាអ្នកស្រីបានប្រើប្រាស់ប័ណ្ណសមធម៌ យ៉ាងណាក្តី អ្នកស្រីសង្កេតឃើញថា ក្រុមគ្រូពេទ្យតែងតែមើលថែយកចិត្ត ទុកដាក់ចំពោះគាត់ និងគ្រួសាររបស់គាត់ ដូចទៅនិងអ្នកជំងឺផ្សេងទៀតផងដែរ។ អ្នកស្រីបានបន្តថាកាលពីមិនទាន់មានប័ណ្ណសមធម៌ គ្រួសាររបស់គាត់មានការលំបាកខ្លាំងជាមួយនឹងជីវភាពរស់នៅប្រចាំថ្ងៃ តែនៅពេលទទួលបានប័ណ្ណសមធម៌ គ្រួសារអ្នកស្រីមានជីវភាពល្អប្រសើជាងមុន។

អ្នកស្រីសំណូមពរឱ្យរាជរដ្ឋាភិបាល បន្តជួយគាំទ្រដល់ពល រដ្ឋខ្វះខាតព្រោះការឧបត្ថមនេះពិតជាបានជួយ សម្រួលដល់ជីវភាពរបស់ពលរដ្ឋក្រីក្រពិតប្រាកដៗណាស់ហើយសូមឱ្យមានដំណើការពិនិត្យមើលលើការផ្តល់ប្រាក់ដល់ប្រជាពលពលរដ្ឋឱ្យបានច្បាស់លាស់ ព្រោះពេលនេះមានប្រជាពលរដ្ឋ មួយចំនួនទទួលបានអត្ថប្រយោជន៍មិនដូចគ្នាទេ ទាំងដែលស្ថានភាពគ្រួសារដូចគ្នា និងកម្រិតជីវភាពក៏ដូចគ្នាផងដែរ។